

# បូរ៉ានិងពិភពផ្សោត

Ban Monineath

Choeurn Bros



នៅក្នុងភូមិមួយក្បែរមាត់ទន្លេ មានគ្រួសារជាច្រើនរស់នៅយ៉ាងកុះករ។ បូរ៉ា ជាក្មេងប្រុសម្នាក់ក្នុងគ្រួសារមួយនៅភូមិនេះ។ ពេលទំនេរ គេតែងចេញទៅជួយឪពុកម្ដាយដឹកអីវ៉ាន់ដើម្បីយកមកលក់។



ព្រឹកមួយពេលកំពុងតែជិះទូកដូចសព្វដង ប៉ូវ៉ាក៏បានជួបកូន ផ្សោតតូចមួយដែលជាប់មងរងរបួសហែលទៅណាមិនរួច។ ដោយក្ដីអាណិត ប៉ូវ៉ាក៏បានជួយកូនផ្សោតនោះ។ ”កុំខ្លាចណា៎! ខ្ញុំនឹងជួយឯង។ ”



រាល់ថ្ងៃបូរ៉ា តែងតែមកផ្តល់ចំណី និងថែទាំកូនផ្សោត។ គេស្រឡាញ់កូនផ្សោតខ្លាំងណាស់។



ថ្ងៃមួយ នៅពេលដែលប៉ូរ៉ាមករកកូនផ្សោតដូចរាល់ដង កូនផ្សោតក៏បាត់ខ្លួន ធ្វើឱ្យប៉ូរ៉ាខកចិត្តយ៉ាងខ្លាំង។



ប៉ូរ៉ាតែងតែមកអង្គុយលេងក្បែរច្រាំងទន្លេជារៀងរាល់ថ្ងៃ សង្ឃឹមថាថ្ងៃណាមួយនឹងបានជួបកូនផ្សោតនោះទៀត។ រហូតដល់ថ្ងៃមួយ ក្ដីសង្ឃឹមរបស់គេក៏ក្លាយជាការពិតមែន ធ្វើឱ្យប៉ូរ៉ាត្រេកអរយ៉ាងខ្លាំង។





កូនផ្សោត មកលើកនេះហាក់ដូចជាចង់នាំ បូរ៉ាទៅកន្លែងមួយ តែដូចជាមានបញ្ហា។ កូនផ្សោតក៏ជ្រមុជទៅក្នុងទឹក រួចងើប មកវិញជាមួយដុំម្យ៉ាង ធ្វើសញ្ញាឱ្យបូរ៉ាលេប ហើយហាក់តោង ខ្លួន ។



ប៉ូរ៉ាលេបដុំនោះ ហើយលោតចូលក្នុងទឹក។ គេក៏លាន់មាត់ ”
អស្ចារ្យណាស់! ខ្ញុំអាចដកដង្ហើមក្នុងទឹកបាន។”



បន្ទាប់មកពួកគេក៏បានហែលរហូតដល់ពិភពផ្សោត ដែលមានផ្សោតជាច្រើន ចេញមកស្វាគមន៍។ ឯមេហ្វូង ក៏បានប្រគល់កែវពិសេសម៉្យាងមកឱ្យបូរ៉ា វាប្រហែលជាអាចជួយដោះស្រាយបញ្ហាណាមួយបាន។ បូរ៉ាបានសួរថា៖ ”តើមានបញ្ហាអ្វី?”



កូនផ្សោតបានបង្ហាញបូរ៉ាពីអ្វីដែលបានកើតឡើង។ ទិដ្ឋភាព ដែលធ្លាប់តែស្រស់ស្អាត ក៏បានប្រែក្លាយជាល្អក់ខ្មៅចខ្មី ។



កូនផ្សោតបានហែលនាំបូរ៉ាទៅខាងលើ។ ផ្ទៃទន្លេមានក្លិនស្អុយ
និងពោរពេញដោយសំរាម។
"តោះឆាប់ឡើងពួកយើង គេចចេញពីទីនេះ!" បូរ៉ាស្រែក។



តែនៅពេលដែលពួកគេត្រៀមនឹងគេចខ្លួន គេក៏ឃើញហ្វូង
ផ្សោតហែលសំដៅមករកពួកគេ។
ទូកនេសាទដ៏ធំពីរកំពុងអូសសំណាញ់សំដៅមករកហ្វូងផ្សោត។



សំណាញ់បានអូសក្រសោបជាប់ទាំង ប៉ូវ៉ា និងហ្វូងផ្សោត ជាច្រើន។ ប៉ូវ៉ាមិនដឹងធ្វើយ៉ាងណាឡើយ។ គេក៏ទាញយកដុំកែវដែលមេផ្សោតឱ្យ មកគ្រវី។ ពន្លឺដ៏ខ្លាំងអស្ចារ្យបានជះឡើង បណ្តាលឱ្យធ្លាយសំណាញ់។



បើកភ្នែកមកវិញ បូរ៉ាឃើញខ្លួនឯងនៅមាត់ច្រាំង ដែលមាន
មនុស្សផ្អើលឈូឆរឈរមើលពន្លឺនៅលើអាកាសជះចេញពីដុំកែវ
។



អ្នកភូមិទាំងមូលបានជួយគ្នាប្រមូលសំរាមចេញពីទន្លេ។ ពួកគេឈប់បង្ហូរកាកសំណល់ប្រេង និងសារធាតុគីមីចូលទៅក្នុងទឹកទៀតហើយ។



បន្ទាប់ពីថ្ងៃនោះមក ប៉ូរ៉ាក៏បានទៅច្រាំងទន្លេចាំមិត្តផ្សោត របស់គេ តែគេមិនបានឃើញកូនផ្សោតទៀតទេតាំងពីថ្ងៃដែល ពួកគេរត់គេចពីសំណាញ់របស់អ្នកនេសាទ។ តើពួកគេទៅណា អស់ហើយ?



មួយរយៈក្រោយមក នៅពេលដែលបូរ៉ាចេញទៅជួយឪពុកម្ដាយ ដូចសព្វដង គេក៏ឃើញហ្វូងផ្សោតលោតសំដៅមករកខ្លួន ដែលធ្វើឱ្យគេត្រេកអរជាពន់ពេក។

"ខ្ញុំនឹកឯងខ្លាំងណាស់ កូនផ្សោត។"



ចាប់ពីពេលនោះមក អ្នកភូមិនាំគ្នារក្សាបរិស្ថានទន្លេ ក៏ដូចជាហ្វូងផ្សោតឱ្យគង់វង្ស។ ភ្ញៀវទេសចរជាច្រើន បានមកទស្សនាហ្វូងផ្សោតនៅទីនេះ។
ឯជីវភាពអ្នកភូមិ ក៏ប្រែមុខមាត់ថ្មី និងរស់នៅសុខសាន្តតរៀងទៅ។



The Asia Foundation

CONSERVATION INTERNATIONAL

អង្គការមូលនិធិសកលសម្រាប់អភិរក្សធនធានធម្មជាតិ (WWF) កំពុងធ្វើការក្នុងប្រទេសកម្ពុជា ដើម្បីការពារសត្វផ្សោត នៅតាមដង ទន្លេមេគង្គ។

សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅ កាន់៖ ://

. . /.

រដ្ឋាភិបាលក៏កំពុងសហការជាមួយអង្គការសម្ព័ន្ធមិត្តសត្វព្រៃ (Wildlife Alliance) ដើម្បីសង្គ្រោះសត្វព្រៃទូទាំងប្រទេស។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់៖ https://www.wildlifealliance.org/tag/wildlife-rapid-rescue-team/

Generously supported by SMART

អនុញ្ញាតឱ្យប្រើប្រាស់ដោយ ក្រសួងអប់រំ យុវជន និងកីឡា

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*បូរ៉ានិងពិភពផ្សោត (Bora Helps His Dolphin Friends)*, Author: Ban Monineath. Illustrator: Choeurn Bros. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC-BY-NC-4.0.

This work is a modified version of the original story. © The Asia Foundation, 2019. Some rights reserved. Released under CC-BY-NC-4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/